2019-05-21

# សមាជិកព្រឹទ្ធសភាអាមេរិក ស្នើច្បាប់ជំរុញការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស



*រូបពីឆ្វេងទៅស្តាំ៖ សមាជិកព្រឹទ្ធសភាអាមេរិកលោក លិនស៊ី ហ្គ្រាហែម (Linsey Graham) លោក ឌិក ឌើប៊ិន (Dick Durbin) និង លោក ម៉ាកូ រូប៊ីអូ (Marco Rubio)*

*គេហទំព័ររបស់ព្រឹទ្ធសភាអាមេរិក*

**លោក មួង ណារ៉េត**

*សមាជិកព្រឹទ្ធសភាអាមេរិកបីរូប រួមគ្នាស្នើច្បាប់ថ្មីមួយ ដើម្បីគាំទ្រការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឲ្យបានពេញលេញ។ សេចក្តីស្នើច្បាប់នេះ ត្រូវដាក់ស្នើ កាលពីថ្ងៃទី១៤ ខែឧសភា តែទើបតែត្រូវបានលេចចេញជាសាធារណៈ នៅថ្ងៃនេះ។*

*សមាជិកព្រឹទ្ធសភាទាំងបីរូបនោះ មួយរូបមកពីខាងគណបក្សសាធារណរដ្ឋលោក លិនស៊ី ហ្គ្រាហែម* (Linsey Graham) *ជាអ្នកផ្តួចផ្តើមស្នើច្បាប់នេះ និង គាំទ្រដោយសមាជិកព្រឹទ្ធសភាអាមេរិកពីររូបទៀត គឺលោក ឌិក ឌើប៊ិន* (Dick Durbin) *ខាងគណបក្សប្រជាធិបតេយ្យ និងលោក ម៉ាកូ រូប៊ីអូ* (Marco Rubio) *ខាងគណបក្សសាធារណរដ្ឋ។*

*ច្បាប់ថ្មីនេះ មានឈ្មោះថា* S.1468 *ដែលទាមទារឲ្យរបបលោក ហ៊ុន សែន ចាត់វិធានការ ឲ្យមានប្រសិទ្ធភាព ដើម្បីការពារសន្តិសុខក្នុងតំបន់ ការពារអធិបតេយ្យភាពរបស់កម្ពុជា កុំឲ្យលុះតាមឥទ្ធិពលរបស់ចិនកុម្មុយនីស្ត និងធ្វើយ៉ាងណាឲ្យកម្ពុជា គោរពសិទ្ធិរបស់ពលរដ្ឋខ្មែរ និងការទទួលខុសត្រូវ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។*

*ច្បាប់នេះ តម្រូវឲ្យរបបលោក ហ៊ុន សែន ដោះលែងប្រធានគណបក្សសង្គ្រោះជាតិលោក កឹម សុខា ជាបន្ទាន់ និង ដោយឥតលក្ខខណ្ឌ ដោះលែងអ្នកទោសនយោបាយ និង សកម្មជនគណបក្សសង្គ្រោះជាតិទាំងអស់ ព្រមទាំងមន្ត្រីអង្គការសង្គមស៊ីវិលផង ហើយទម្លាក់ចោលរាល់បទចោទប្រកាន់លើពួកគាត់។ ទម្លាក់ចោលរាល់ការចោទប្រកាន់ ដោយហេតុផលនយោបាយ លើមេដឹកនាំផ្សេងទៀត*

របស់បក្សប្រឆាំង ដូចជាលោក សម រង្ស៊ី និង ទម្លាក់ចោលបទចោទលើអតីតអ្នកយកព័ត៌មានអាស៊ីសេរីពីររូបផង គឺលោក អ៊ួន ឈិន និង លោក យាង សុជាមិត្ត។

ម្យ៉ាងទៀត របបលោក ហ៊ុន សែន ត្រូវតែលុបចោលច្បាប់វិសោធនកម្ម ស្ដីពីគណបក្សនយោបាយ ដើម្បីអនុញ្ញាតឲ្យគណបក្សប្រឆាំងបើកដំណើរការឡើងវិញ និង ផ្ដល់នីតិសម្បទា ដល់មន្ត្រីជាន់ខ្ពស់បក្សប្រឆាំងទាំងអស់ ដែលរងបម្រាម សិទ្ធិនយោបាយ ពីសំណាក់របបនេះ។

ក្នុងករណីរបបនេះ មិនអនុវត្តតាម រដ្ឋាភិបាលសហរដ្ឋអាមេរិក ត្រូវដាក់ទណ្ឌកម្មលើមន្ត្រីរបបនេះ រួមមាន ទីមួយគឺបង្កកទ្រព្យសម្បត្តិមន្ត្រីទាំងនោះ ទីពីរគឺព្យួរការអនុគ្រោះពន្ធទូទៅ ឬ GSP និងទីបី គឺមិនបន្ធូរបន្ថយចំពោះការជំពាក់បំណុល អាមេរិក៕